# ឧបសម្ព័ន្ធ៦-ក
# កិច្ចសហប្រតិបត្តិការដើម្បីកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ច នៃជំងឺរាតត្បាតជាសកល[1]

## បទប្បញ្ញត្តិទូទៅ

១. គូភាគីទទួលស្គាល់ថាមេរោគកូរ៉ូណា (កូវីដ-១៩) បានបង្កបញ្ហាប្រឈមជាសកលយ៉ាងធ្ងន់ធ្ងរ និងពុំធ្លាប់មានពីមុនមក ដល់សុខភាព ជីវភាពរស់នៅ និងសុវត្ថិភាពរបស់មនុស្ស ដែលតម្រូវឱ្យមានកិច្ចសម្របសម្រួលរកដំណោះស្រាយ ដើម្បីធានាដល់ការបន្តលំហូរនៃទំនិញ សេវាកម្ម និងមនុស្ស ក្នុងខ្សែច្រវ៉ាក់ផ្គត់ផ្គង់សកល។

២. គូភាគីទទួលស្គាល់នូវសក្តានុពលសម្រាប់ការអភិវឌ្ឍសកម្មភាពសមស្រប ដែលពង្រឹងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមនៃជំងឺរាតត្បាតជាសកល ដោយរក្សាទុកនូវភាពបត់បែននៃលំហរគោលនយោបាយ ស្របជាមួយគោលដៅអភិវឌ្ឍន៍របស់គូភាគី។

## ការធ្វើកិច្ចការដើម្បីធានានូវលំហូរទំនិញក្នុងខ្សែច្រវ៉ាក់ផ្គត់ផ្គង់សកល

៣. គូភាគីទទួលស្គាល់នូវសារៈសំខាន់នៃកិច្ចសម្រួលឲ្យបានទាន់ពេលពេលវេលា តាមដែលអាចធ្វើទៅបានចំពោះការដឹកជញ្ជូន និងការបញ្ចេញទំនិញពីគយ សម្រាប់ទំនិញចាំបាច់ រួមមាន ចំណីអាហារ បរិក្ខារពេទ្យសំខាន់ៗ និងសំភារៈការពារខ្លួន ដោយអនុលោមតាម *កិច្ចព្រមព្រៀង ស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម* ដូចមានចែងក្នុង ឧបសម្ព័ន្ធ១ក នៃកិច្ចព្រមព្រៀង WTO និងច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក។

៤. គូភាគីត្រូវព្យាយាមជៀសវាងនូវការដាក់ការហាមឃាត់ ការរឹតបន្តឹង ឬរបាំងមិនមែនពន្ធគយ លើការនាំចេញទំនិញចាំបាច់ រួមទាំង ចំណីអាហារ ថ្នាំពេទ្យ និងបរិក្ខារពេទ្យសំខាន់ៗ ដោយធានាឱ្យបានថាវិធានការទាំងនោះចំគោលដៅ មានសមាមាត្រ មានតម្លាភាព មានរយៈពេលខ្លី និងមានសង្គតិភាពស្របតាមវិធានរបស់អង្គការ WTO។

## កិច្ចសម្រួលបម្លាស់ទីដែលចាំបាច់សម្រាប់បុគ្គល

៥. គូភាគីទទួលស្គាល់ពីសារៈសំខាន់នៃកិច្ចសម្រួលបម្លាស់ទីដែលចាំបាច់សម្រាប់បុគ្គល តាមដែលអាចធ្វើទៅបាន រួមទាំង ការធ្វើដំណើរធុរកិច្ចឆ្លងកាត់ព្រំដែន ខណៈពេលដែលធានានូវវិធានការសុខភាពសាធារណៈ ដែលស្របជាមួយនឹងកិច្ចខំប្រឹងប្រែង ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតជាសកល ក៏ដូចជាកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមនៃជំងឺរាតត្បាតជាសកល។

៦. គូភាគីទទួលស្គាល់ផងដែលនូវអត្ថប្រយោជន៍នៃការបង្កើតសេចក្តីណែនាំ ដើម្បីផ្តល់ការគាំទ្រ និងជំនួយចំពោះគ្នាទៅវិញទៅមក និងដើម្បីជំរុញកិច្ចសម្រួលបម្លាស់ទី ដែលចាំបាច់សម្រាប់បុគ្គលរួម

---

1 "**ជំងឺរាតត្បាតជាសកល**" សំដៅទៅលើជំងឺមួយដែលអង្គការសុខភាពពិភពលោក (WHO) បានប្រកាសពីការរីករាលដាលនៃជំងឺរាតត្បាតជាសកល រួមមានជំងឺកូវីដ-១៩ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០។

ទាំង ការធ្វើដំណើរឆ្លងកាត់ព្រំដែនដែលចាំបាច់ ដើម្បីធានាឱ្យបាននូវការបន្តដំណើរការធុរកិច្ច ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក និងដោយមិនប៉ះពាល់ដល់កិច្ចខំប្រឹងប្រែងក្នុងការពារការរីករាលនៃមេរោគនេះ។

៧. គូភាគីត្រូវព្យាយាមពង្រឹងកិច្ចសហប្រតិបត្តិការ ដើម្បីផ្តល់ការគាំទ្រ និងជំនួយសមស្រប ទៅដល់ប្រជាជននៃប្រទេសទាំងពីរ ជាពិសេស ជនងាយរងគ្រោះដែលរស់នៅ បំពេញការងារ និងសិក្សានៅក្នុងប្រទេសនីមួយៗ ដោយផ្តោតលើភាពថ្លៃថ្នូរ សុខភាព សុខុមាលភាព សុវត្ថិភាព និងការយកចិត្តទុកដាក់ដោយស្មើភាព និងប្រសិទ្ធភាព ដល់ជនដែលទទួលរងផលប៉ះពាល់ដោយជំងឺរាតត្បាតជាសកល ព្រមទាំងធ្វើកិច្ចសម្រួលបម្លាស់ទីដែលចាំបាច់សម្រាប់បុគ្គល។

**ពង្រឹងសាមគ្គីភាពដើម្បីគ្រប់គ្រងការរីករាលដាលនៃជំងឺរាតត្បាតជាសកល**

៨. គូភាគីទទួលស្គាល់ថាការដោះស្រាយបញ្ហាជំងឺរាតត្បាតជាសកល តម្រូវឱ្យមានសាមគ្គីភាព និងកិច្ចខំប្រឹងប្រែងជាសកល និងបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរួមគ្នា ដើម្បីពង្រឹងសាមគ្គីភាព និងការគាំទ្រគ្នាទៅវិញទៅមក ក្នុងការគ្រប់គ្រងការរីករាលដាលនៃជំងឺរាតត្បាតជាសកលនេះ ដោយកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់សង្គម និងសេដ្ឋកិច្ចរបស់គូភាគីទាំងពីរ។

៩. គូភាគីទទួលស្គាល់ពីសារៈសំខាន់នៃការចែករំលែកព័ត៌មាន និងបទពិសោធន៍ ដើម្បីការពារ និងគ្រប់គ្រងការរីករាលដាលនៃជំងឺរាតត្បាតជាសកលនេះ។

**កាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់អវិជ្ជមានលើពាណិជ្ជកម្ម និងការវិនិយោគ ដែលបណ្តាលមកពីជំងឺរាតត្បាតជាសកល ដើម្បីសម្រួលការស្តារសេដ្ឋកិច្ចឡើងវិញប្រកបដោយបរិយាប័ន្ន ចីរភាព និងភាពធន់**

១០. គូភាគីត្រូវព្យាយាមអភិវឌ្ឍ និងអនុវត្តសកម្មភាពកិច្ចសហប្រតិបត្តិការ ដើម្បីកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់អវិជ្ជមានលើពាណិជ្ជកម្ម និងការវិនិយោគដែលកើតឡើងពីជំងឺរាតត្បាតជាសកល ដូចបានព្រមព្រៀងរវាងគូភាគី។

១១. គូភាគីត្រូវព្យាយាមផ្តល់ព័ត៌មានពាក់ព័ន្ធ និងឧត្តមានុវត្តន៍ឱ្យបានទាន់ពេលវេលា តាមដែលធ្វើទៅបាន នៅពេលចាត់វិធានការណាមួយ ដែលអាចមើលដឹងពីផលប៉ះពាល់ដល់ពាណិជ្ជកម្ម និងការវិនិយោគអន្តរជាតិ ។

១២. គូភាគីត្រូវព្យាយាមអនុវត្តគំនិតផ្តួចផ្តើមរួម ជាមួយនឹងភាគីពាក់ព័ន្ធ ដែលរួមចំណែកក្នុងការសម្រួលការស្តារសេដ្ឋកិច្ចឡើងវិញប្រកបដោយបរិយាប័ន្ន ចីរភាព និងភាពធន់។